# មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ




## តាកែវ, ថ្ងៃទី ១៩-២០ ខែ សីហា ឆ្នាំ ២០១០

## បន្ទប់ប្រជុំរបស់មន្ទីរសុខាភិបាលខេត្ត

**រៀបចំដោយ** **ឧបត្ថម្ភដោយ**

## ១~ សមាសភាពចូលរួមមាន :

គណៈអធិបតីដែលចូលរួមក្នុងពិធីបើកកិច្ចប្រជុំនេះមាន:

- O ឯកឧត្តមវេជ្ជ.**មាន ឈីវុន** ប្រធានមជ្ឈប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ
- O ឯកឧត្តមវេជ្ជ. **ម៉ៅ តាន់អ៊ាង** ប្រធានមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន
- O លោកវេជ្ជ. **នុត ស៊ីណាត** អនុប្រធានមន្ទីរសុខាភិបាលខេត្តតាកែវ

សិក្ខាកាមដែលចូលរួម មានចំនួន ៧៥ រូប ដែលជាសមាជិកក្រុមថែទាំ-ព្យាបាលជំងឺអេដស៍ លើកុមារ និងមនុស្សពេញវ័យ ,សេវាជំងឺរបេង,មន្ទីរពិសោធន៍,ក្រុមថែទាំតាមផ្ទះ,អ្នកសំរបសំរួល MMM និង mmm អ្នកផ្តល់ប្រឹក្សាផ្ទៃក VCCT ដែលអញ្ជើញមកពីមន្ទីរពេទ្យបង្អែកគីរីវង់ និង មន្ទីរពេទ្យបង្អែកអង្គ រកា ខេត្តតាកែវ និងមន្ទីរពេទ្យបង្អែកជ័យជំនះ ខេត្តកណ្តាល ។

## ២~ អ្នកសំរបសំរួលវគ្គ/អ្នកចូលរួម :

១- លោកវេជ្ជ. មាស វុឌ្ឍី អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ

| | |
|---|---|
| ២- លោកវេជ្ជ. សេង សុភាព | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ |
| ៣- លោកស្រីវេជ្ជ. ស៊ុយ ដូនីន | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ |
| ៤- លោកវេជ្ជ. ស៊ឹម សុផៃ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ |
| ៥- លោក កែវ វណ្ណៈ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ |
| ៦- លោក ផាត់ វាសនា | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ |
| ៧- លោកវេជ្ជ. ឃុន គីមអ៊ាម | មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន |
| ៨- លោកវេជ្ជ. ជា ម៉ានិត | មជ្ឈមណ្ឌលជាតិ កំចាត់រោគរបេង និងហង់សិន |
| ៩- លោកវេជ្ជ. ជុំ ចាន់ផន | មជ្ឈមណ្ឌលជាតិ កំចាត់រោគរបេង និងហង់សិន |
| ១០- លោកវេជ្ជ. គៀន សុរិយា | មជ្ឈមណ្ឌលជាតិ កំចាត់រោគរបេង និងហង់សិន |

## ៣~ សកម្មភាព :

### គោលបំណង:

- ផ្តល់ពតិមាន ស្តីពីខ្លឹមសារនៃនិយាមបែបបទ សំរាប់អនុវត្តការបង្កើតការស្រាវជ្រាវ រកករណីជំងឺរបេង ការព្យាបាលបង្ការជំងឺរបេងដោយឱសថ Isoniazid និងការបង្ការការចំលងមេរោគរបេងនៅតាមបណ្តាសេវាថែទាំ និងព្យាបាលបន្ត សំរាប់អ្នកផ្ទុក មេរោគអេដស៍ ។
- បង្កើនចំណេះដឹង និងជំនាញចាំបាច់ទាក់ទងនឹងការអនុវត្តន៍យុទ្ធសាស្រ្ត 3I's ជូនដល់មន្រ្តីផ្តល់សេវាថែទាំ-ព្យាបាល សំរាប់អ្នកផ្ទុកមេរោគអេដស៍ ដោយផ្តោតលើ ប្រធានបទខាងក្រោម:

១- បង្កើនការស្រាវជ្រាវអ្នកជំងឺរបេងថ្មី ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ថ្មី តាមរយៈការសាកសួររករោគសញ្ញាទាំងបី
២- ការប្រើប្រាស់គំនូសបំព្រួញសំរាប់ការផ្តល់ការព្យាបាលបង្ការជំងឺរបេងដោយ ប្រើឱសថ Isoniazid (IPT)
៣- ការពិនិត្យសុខភាពរករោគសញ្ញាជំងឺរបេងដោយប្រើប័ណ្ណពិនិត្យសុខភាពរក រោគសញ្ញាជំងឺរបេងសំរាប់អ្នកផ្ទុកមេរោគអេដស៍ និងការព្យាបាលបង្ការជំងឺរបេង ដោយប្រើឱសថ Isoniazid (IPT)
៤- ការធ្វើរោគវិនិច្ឆ័យច្បាស់លាស់ (diagnostic workup) រកជំងឺរបេងក្នុង ចំណោមអ្នកផ្ទុកមេរោគអេដស៍
៥- ការផ្តល់ការគាំទ្រសំរាប់ការប្រើប្រាស់ឱសថ Isoniazid ឱ្យបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ ក្នុងការផ្តល់ IPT
៦- ការបង្ការការចំលងមេរោគរបេងនៅតាមបណ្តាសេវាថែទាំ និងព្យាបាលបន្ត
៧- ការប្រមូលទិន្នន័យ ដោយប្រើឧបករណ៏ត្រួតពិនិត្យតាមដាននៃនិយាមនៃ បែបបទសំរាប់អនុវត្តយុទ្ធសាស្ត្រ 3Is

- រៀបចំផែនការ សំរាប់យុទ្ធសាស្ត្រ 3Is នៅសេវាថែទាំ-ព្យាបាលបន្ត សំរាប់អ្នកផ្ទុក មេរោគអេដស៍ មន្ទីរពេទ្យបង្អែកគីរីវង់ និង មន្ទីរពេទ្យបង្អែកអង្គ រកា ខេត្តតាកែវ និងមន្ទីរពេទ្យបង្អែកជ័យជំនះ ខេត្តកណ្តាល ។

## ថ្ងៃទី១: ១៩ ខែ សីហា ២០១០

- មតិស្វាគមន៏របស់ **លោកវេជ្ជ នុត ស៊ីណាត** អនុប្រធានមន្ទីរសុខាបាលខេត្តតាកែវ
- ចំណាប់អារម្មណ៏របស់ **ឯកឧត្តមវេជ្ជ. ម៉ៅ តាន់អ៊ាង** ប្រធានមជ្ឍមណ្ឌលជាតិ កំចាត់រោគរបេង និងហង់សិន
- ចំណាប់អារម្មណ៏ និងពិធីបើកកិច្ចប្រជុំដោយ **ឯកឧត្តមវេជ្ជ. មាន ឈីវុន** ប្រធានមជ្ឍមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

☞ ការបង្ហាញពីកម្មវិធី និងគោលនៃកិច្ចប្រជុំ ដោយ**លោកវេជ្ជ. សេង សុភាព**

☞ ការបង្ហាញពីផ្តល់ពតិមាន ស្តីពីខ្លឹមសារនៃនិយាមបែបបទ សំរាប់អនុវត្តការបង្កើតការ ស្រាវជ្រាវរកករណីជំងឺរបេង ការព្យាបាលបង្ការជំងឺរបេងដោយឱសថ Isoniazid និងការបង្ការការចំលងមេរោគរបេង នៅតាមបណ្តាសេវាថែទាំ និងព្យាបាលបន្ត សំរាប់អ្នកផ្ទុកមេរោគ អេដស៍ ដោយ**លោកវេជ្ជ. ស៊ឹម សុផៃ និង យុន គីម អ៊ាម**

☞ ការពិភាក្សាទូទៅ **សំរបសំរួលដោយមន្ត្រី** NCHADS & CENAT

☞ ការព្យាបាលបង្ការជំងឺរបេងដោយឱសថ soniazid បង្ហាញដោយ **លោកវេជ្ជ. ឃុន គីមអ៊ាម**

☞ ការពិនិត្យសុខភាពរករោគសញ្ញាជំងឺរបេងដោយប្រើបណ្ណ័ពិនិត្យសុខភាពរោគ សញ្ញាជំងឺរបេង បង្ហាញដោយ **លោកវេជ្ជ. ស៊ឹម សុផៃ/ លោក កែវ វណ្ណះ**

☞ ការធ្វើរោគវិនិច្ឆ័យច្បាស់លាស់ (Diagnostic Workup) រកជំងឺរបេង បង្ហាញដោយ **លោកវេជ្ជ. ឃុន គីម អ៊ាម/ជា ម៉ានិត**

☞ ការផ្តល់ការគាំទ្រ សំរាប់ការប្រើប្រាស់ឱសថ អោយបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់ ក្នុងការផ្តល់ការព្យាបាលបង្ការជំងឺរបេង ដោយឱសថ Isoniazid បង្ហាញដោយ **លោកវេជ្ជ. សេង សុភាព និងលោក កែវ វណ្ណះ**

## ថ្ងៃទី២: ២០ ខែ សីហា ២០១០

☞ ការបង្ការការចំលងមេរោគរបេង នៅតាមបណ្តាសេវា ថែទាំ-ព្យាបាលបន្ត បង្ហាញដោយ **លោកវេជ្ជ. ជា ម៉ានិត/គៀន សុរិយា**

☞ ការប្រមូលទិន្នន័យ ដោយប្រើឧបករណ៏ ត្រួតពិនិត្យតាមដាននៃ និយាមនៃបែបបទ សំរាប់ អនុវត្តយុទ្ធសាស្ត្រ Three I's បង្ហាញដោយលោក **ផាត់ វាសនា/កែវ វណ្ណះ**

☞ ការពិភាក្សាជាក្រុម: **ការលើកផែនការ សំរាប់អនុវត្តនូវសកម្មភាពនៃការ អនុវត្តន៏យុទ្ធសាស្ត្រ** Three I's **នៅសេវាថែទាំ-ព្យាបាលបន្ត** សំរបសំរួលដោយមន្ត្រី NCHADS និង CENAT

☞ ការបង្ហាញពីលទ្ធផលនៃការពិភាក្សាជាក្រុម **សំរបសំរួលដោយមន្ត្រី** NCHADS និង CENAT

☞ សិក្ខាកាមនៃស្រុកប្រតិបត្តិទាំងពីរ បានឯកភាពគ្នា នឹងចាប់ផ្តើមដំណើរ នូវយុទ្ធសាស្ត្រ 3 Is នេះ ក្នុងខែ កក្កដា ឆ្នាំ ២០១០ បន្ទាប់ពី មជ្ឈមណ្ឌលទាំងពីផ្គត់ផ្គង់ សំភារៈ និងឱសថ រួចរាល់។

## លទ្ធផលនៃការវាយតំលៃកិច្ចប្រជុំ :

| | វែងពេក | សមរម្យ | ខ្លី | ខ្លីពេក |
|---|---|---|---|---|
| ១. រយៈពេល | ០០ | ៥៥ | ០៤ | ០១ |
| | **ល្អ** | **បង្គួរ** | **មធ្យម** | **ខ្វះខាត** |
| ២. ទីកន្លែង | ០០ | ៤៥ | ១៥ | ០០ |
| ៣. ការរៀបចំវគ្គបណ្តុះបណ្តាល | ១៥ | ៣០ | ១៥ | ០០ |
| ៤. ខ្លឹមសារមេរៀន | ៤៣ | ១៥ | ០២ | ០០ |

| | | | | |
|---|---|---|---|---|
| ៥. ការបង្រៀន និងការសំរបសំរួល | ២៧ | ១៣ | ១០ | ០០ |
| ៦. ឯកសារសំរាប់សិក្ខាកាម | ០៥ | ៤៥ | ០៤ | ០៦ |

៧. ចំណេះដឹង និងជំនាញ ចំនួន បី ដែលសិក្ខាកាមបានទទួលពីវគ្គបណ្តុះបណ្តាល

៧.១- ចំណេះដឹង

- ដឹងពីយុទ្ធសាស្ត្រ 3Is
- ការប្រើប្រាស់ឱសថ Isoniazid
- ការគ្រប់គ្រងការចំលង

៧.២- ជំនាញ

- រោគសញ្ញារបេង
- កែសំរួលប្រពន្ធ័ខ្យល់
- ការផ្តល់ឱសថ អ៊ីសូឌីញ៉ាស៊ីដ
- បញ្ជូនរបាយការណ៍

៨. តើមានប្រធានបទណាខ្លះ ដែលអ្នកចង់ដាក់បញ្ចូលបន្ថែមទៀត នៅក្នុងសិក្ខាសាលា?

២. ប្រធានបទ ស្តីពីការថត X-Ray

៣. ការព្យាបាលដោយឱសថ OI/ART លើស្ត្រីមានផ្ទៃពោះ

៩. តើអ្នកយល់ថា ត្រូវកែលំអវគ្គសិក្ខាសាលានេះ យ៉ាងដូចម្តេច ដើម្បីអោយមានលក្ខណៈប្រសើរសំរាប់វគ្គក្រោយៗទៀត?

១. រយៈពេលខ្លីពេក

២. អក្សរក្នុង Slides ខ្លះ មើលមិនច្បាស់ ( អក្សរតូចពេក)

១០. សំណូមពរ សំរាប់វគ្គក្រោយ

១. សុំប្រាក់លើកទឹកចិត្ត

២. ចុះបង្ហាញដល់មន្ទីរពេទ្យ

៣. សុំអោយអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ចូលរួមផង

៤. សុំចុះអភិបាលអោយបានញឹកញាប់

៥. សុំអោយប្រធានមន្ទីរពេទ្យចូលរួមផង

៦. សុំអោយប្រធាន/អនុប្រធានកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ចូលរួមផង

ពិធីបិទវគ្គប្រព្រឹត្តទៅ ដោយមានវត្តមានគណអធិបតីរចូលរួមដូចជា

- ឯកឧត្តមវេជ្ជ.**មាន ឈីវុន** ប្រធានមជ្ឈប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ
- ឯកឧត្តមវេជ្ជ. **ម៉ៅ តាន់អ៊ាង** ប្រធានមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន
- លោកវេជ្ជ. **នុត ស៊ីណាត** អនុប្រធានមន្ទីរសុខាភិបាលខេត្តតាកែវ

កិច្ចប្រជុំនេះបានបញ្ចប់ដោយជោគជ័យនៅវេលាម៉ោង ៥និង ០០ នាទី ល្ងាច បន្ទាប់ពីបានបូកសរុបកិច្ចប្រជុំ និងការថ្លែងសុន្ទរកថាបិទដោយ ឯកឧត្តមវេជ្ជ. **មាន ឈីវុន** ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺ អេដស៍ សើស្បែក និងកាមរោគ។

បានឃើញ និងឯកភាព
ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធ
នឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

វេជ្ជ មាន ឈីវុន

ភ្នំពេញថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១០
អ្នកធ្វើរបាយការណ៍

លោក កែវ វណ្ណៈ